# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
# នីតិកាលទី៦ ឆ្នាំ២០១៨




*ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ប្រព្រឹត្តទៅនៅ**ថ្ងៃអាទិត្យ ទី២៩ ខែកក្កដា ឆ្នាំ២០១៨**។*




១
តើការបោះឆ្នោតជ្រើសតាំង
តំណាងរាស្ត្រធ្វើតាមប្រព័ន្ធណា?
២
ការបោះឆ្នោតជ្រើសតាំង
តំណាងរាស្ត្រត្រូវធ្វើតាមប្រព័ន្ធសមាមាត្រ
តាមរាជធានី ខេត្ត ដោយយករាជធានី ខេត្ត
ជាមណ្ឌលបោះឆ្នោត ។


តើអាសនៈនៅក្នុងរដ្ឋសភា
មានចំនួនប៉ុន្មាន?
ហើយបែងចែកយ៉ាងដូចម្ដេច?

អាសនៈនៅក្នុងរដ្ឋសភាមានចំនួន ១២៥ ដែលបែងចែកតាមមណ្ឌលរាជធានី ខេត្ត ដូចខាងក្រោម ៖

០១. មណ្ឌលខេត្តបន្ទាយមានជ័យ ចំនួន ០៦ អាសនៈ
០២. មណ្ឌលខេត្តបាត់ដំបង ចំនួន ០៨ អាសនៈ
០៣.មណ្ឌលខេត្តកំពង់ចាម ចំនួន ១០ អាសនៈ
០៤. មណ្ឌលខេត្តកំពង់ឆ្នាំង ចំនួន ០៤ អាសនៈ
០៥. មណ្ឌលខេត្តកំពង់ស្ពឺ ចំនួន ០៦ អាសនៈ
០៦. មណ្ឌលខេត្តកំពង់ធំ ចំនួន ០៦ អាសនៈ
០៧. មណ្ឌលខេត្តកំពត ចំនួន ០៦ អាសនៈ
០៨. មណ្ឌលខេត្តកណ្ដាល ចំនួន ១១ អាសនៈ
០៩. មណ្ឌលខេត្តកោះកុង ចំនួន ០១ អាសនៈ
១០. មណ្ឌលខេត្តក្រចេះ ចំនួន ០៣ អាសនៈ
១១. មណ្ឌលខេត្តមណ្ឌលគិរី ចំនួន ០១ អាសនៈ
១២. មណ្ឌលរាជធានីភ្នំពេញ ចំនួន ១២ អាសនៈ
១៣.មណ្ឌលខេត្តព្រះវិហារ ចំនួន ០១ អាសនៈ
១៤. មណ្ឌលខេត្តព្រៃវែង ចំនួន ១១ អាសនៈ
១៥. មណ្ឌលខេត្តពោធិ៍សាត់ ចំនួន ០៤ អាសនៈ
១៦. មណ្ឌលខេត្តរតនគិរី ចំនួន ០១ អាសនៈ
១៧. មណ្ឌលខេត្តសៀមរាប ចំនួន ០៦ អាសនៈ
១៨. មណ្ឌលខេត្តព្រះសីហនុ ចំនួន ០៣ អាសនៈ

| | |
|---|---|
| ១៩. មណ្ឌលខេត្តស្ទឹងត្រែង | ចំនួន ០១ អាសនៈ |
| ២០. មណ្ឌលខេត្តស្វាយរៀង | ចំនួន ០៥ អាសនៈ |
| ២១. មណ្ឌលខេត្តតាកែវ | ចំនួន ០៨ អាសនៈ |
| ២២. មណ្ឌលខេត្តកែប | ចំនួន ០១ អាសនៈ |
| ២៣.មណ្ឌលខេត្តប៉ៃលិន | ចំនួន ០១ អាសនៈ |
| ២៤. មណ្ឌលខេត្តឧត្តរមានជ័យ | ចំនួន ០១ អាសនៈ |
| ២៥. មណ្ឌលខេត្តត្បូងឃ្មុំ | ចំនួន ០៨ អាសនៈ |

# ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត

*អនុលោមតាមមាត្រា ១៦៧ នៃ ច.ប.ត.រ គ.ជ.ប ត្រូវរៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ។ ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ ត្រូវអនុវត្តតាម ច.ប.ត.រ និងបទបញ្ជា និងនីតិវិធីសម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតឆ្នាំ២០១៧ របស់ គ.ជ.ប ។*





តើ គ.ជ.ប បិទផ្សាយបញ្ជីបោះឆ្នោត និង
បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត
នៅពេលណា? និងនៅកន្លែងណា?

គ.ជ.ប នឹងបិទផ្សាយបញ្ជីបោះឆ្នោត និងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត នៅគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត (**គឃ.សប**) **នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨** ហើយនិងបិទផ្សាយនៅតាមការិយាល័យបោះឆ្នោត **នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨** គឺ ១ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

គ.ជ.ប បានផ្សព្វផ្សាយជាសាធារណៈ
នូវបញ្ជីបោះឆ្នោត និងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត
តាមរយៈគេហទំព័រ គ.ជ.ប ៖ www.voterlist.org.kh ។



# លក្ខខណ្ឌសម្រាប់អ្នកបោះឆ្នោត



ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋ
ទាំងពីរភេទ ត្រូវមានលក្ខខណ្ឌអ្វីខ្លះ?

ដើម្បីបោះឆ្នោតបានក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ នេះ ប្រជាពលរដ្ឋទាំងពីរភេទ ត្រូវមានលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ដែលបានផ្តល់សុពលភាពដោយ គ.ជ.ប សម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ ។
- មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ **(អ.ខ)** ប្រភេទទី១ ឬទី២ ឬទី៣ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត **(ឯ.អ)** ឬឯកសាបញ្ជាក់អត្តសញ្ញាណ បម្រើឱ្យការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ **(ឯ.អ)** ដែលមានបញ្ជាក់ពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៧ ដោយ **គឃ.សប** ។

ប្រភេទទី ១



ឬ

ប្រភេទទី ២



ប្រភេទទី ៣

ឬ






ប្រជាពលរដ្ឋដែលស្នើសុំ ឯ.អ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

- ត្រូវស្នើសុំ ឯ.អ ក្នុងរយៈពេល ៣០ថ្ងៃ មុនថ្ងៃបោះឆ្នោត និងបញ្ចប់ ១ថ្ងៃ មុនថ្ងៃបោះឆ្នោត ។
- ត្រូវបង្ហាញខ្លួនផ្ទាល់នៅមុខ គឃ.សប និងអាជ្ញាធរឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវបោះឆ្នោត ។
- ត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

N° X XXX XXX

រូបថត ៣x៤

- *យករូបថតទំហំ ៣x៤ ចំនួន ០៣សន្លឹក ថតចំពីមុខ បង្ហាញមុខ និង ស្មា និងនាំសាក្សី ០២រូប មកបង្ហាញខ្លួននៅចំពោះមុខ* ***គឃ.សប*** *។*
- *បំពេញលិខិតស្នើសុំ ហើយត្រូវផ្តិតមេដៃនៅចំពោះមុខ* ***គឃ.សប*** *។*
- *ត្រូវបន្តយកលិខិតស្នើសុំ និងចុងទម្រង់ ឯ.អ បម្រើឱ្យការបោះឆ្នោត ០២សន្លឹក ពី* ***គឃ.សប*** *ទៅជូនមេឃុំ ចៅសង្កាត់ ពិនិត្យសម្រេច ចេញជូន ។*






ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Nº XXXXXXX

រាជធានី ខេត្ត .....................
ក្រុង ស្រុក ខណ្ឌ .................
ឃុំ សង្កាត់ .........................
លេខ .................................

ឯកសារបញ្ជាក់អត្តសញ្ញាណ
បម្រើឱ្យការចុះឈ្មោះបោះឆ្នោត

រូបថត
៣x៤

យោងលិខិតស្នើសុំរបស់សាមីខ្លួនចុះថ្ងៃទី...........ខែ...........ឆ្នាំ............
យើងមេឃុំ ចៅសង្កាត់ ☐ ជំទប់/ចៅសង្កាត់រងទទួលសិទ្ធិ ☐ ...........................................
ចេញឯកសារបញ្ជាក់អត្តសញ្ញាណឱ្យឈ្មោះ...................................ភេទ...........សញ្ជាតិ..............
កើតនៅថ្ងៃទី...........ខែ..........ឆ្នាំ...........មានលំនៅឋាន ឬទីសំណាក់លេខ................ផ្លូវ...............
ភូមិ........................ ក្នុងឃុំ សង្កាត់នេះ ប្រើប្រាស់សម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ ។
......................ថ្ងៃទី.......... ខែ......... ឆ្នាំ...........
ហត្ថលេខា ឈ្មោះ និងត្រាឃុំ សង្កាត់

ឯកសារនេះអាចប្រើប្រាស់បម្រើឱ្យការបោះឆ្នោតបាន ប៉ុន្តែត្រូវឱ្យ
សាមីខ្លួនទៅសុំបញ្ជាក់សុពលភាពពី គឃ.សប នៅមុនថ្ងៃបោះឆ្នោត

# ដំណើរប្រព្រឹត្តទៅនៃការបោះឆ្នោត




*ការិយាល័យបោះឆ្នោតចាប់ផ្ដើមបើកឱ្យអ្នកបោះឆ្នោតចូលទៅបោះឆ្នោតចាប់ពី**ម៉ោង ៧:០០ នាទីព្រឹក** ដល់ **ម៉ោង ៣:០០ នាទីរសៀល** ។ ការបោះឆ្នោតត្រូវធ្វើតែ ១ថ្ងៃ ។*




- *ប្រសិនបើអ្នកបោះឆ្នោតមានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នោះពេលចូលក្នុងការិយាល័យបោះឆ្នោត គាត់អាចយកប័ណ្ណព័ត៌មាននោះជូនទៅលេខាធិការ ដើម្បីពិនិត្យមើលលេខរៀងឈ្មោះរបស់គាត់ក្នុងបញ្ជីបោះឆ្នោត ។*

– ក្នុងករណីអ្នកបោះឆ្នោតពុំមានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត នៅពេលទៅដល់ការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតត្រូវទៅរកមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោត ដែលត្រូវបានបិទនៅមុខការិយាល័យបោះឆ្នោត ដើម្បីឱ្យប្រាកដថា ឈ្មោះរបស់ខ្លួនស្ថិតក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។






អ្នកបោះឆ្នោតស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត ដែលបិទនៅមុខការិយាល័យបោះឆ្នោត

នៅពេលបានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតត្រូវទៅជួបលេខាធិការមុនគេ ។

- *លេខាធិការត្រួតពិនិត្យម្រាមដៃអ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថា គ្មានស្នាមទឹកខ្មៅលុបមិនជ្រះ ។*
- *អ្នកបោះឆ្នោត ត្រូវប្រគល់ **អ.ខ** ឬ **ឯ.អ** និងប័ណ្ណព័ត៌មានអ្នកបោះឆ្នោតឱ្យលេខាធិការ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត ។*

ក្នុងករណី អ្នកបោះឆ្នោតពុំមានប័ណ្ណព័ត៌មានអ្នកបោះឆ្នោតទេ គាត់ត្រូវប្រាប់លេខរៀងរបស់ខ្លួនទៅលេខាធិការ ដើម្បីងាយស្រួលក្នុងការរកឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

បន្ទាប់មក លេខាធិការប្រាប់ឱ្យអ្នកបោះឆ្នោត គូសសញ្ញាធិចទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោត ដើម្បីបញ្ជាក់ការបានមកបោះឆ្នោតរបស់អ្នកបោះឆ្នោត ។





**លេខាធិការពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត**

*បន្ទាប់មក លេខាធិការប្រាប់ឱ្យអ្នកបោះឆ្នោតទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន ដែលនៅអង្គុយខាងស្តាំដៃគាត់ ។*






អនុប្រធានបោះត្រាសម្ងាត់នៅផ្នែកខាងខ្នងនៃសន្លឹកឆ្នោត
និងប្រគល់សន្លឹកឆ្នោតទៅអ្នកបោះឆ្នោត

បន្ទាប់មក អ្នកបោះឆ្នោត
ត្រូវដើរទៅកាន់បន្ទប់សម្ងាត់ណាមួយដែលទំនេរ
ដើម្បីចូលទៅគូសសន្លឹកឆ្នោត ។

នៅក្នុងបន្ទប់សម្ងាត់នេះ
គ្មានអ្នកណាដឹងថា អ្នកបោះឆ្នោតគូសសញ្ញា
គាំទ្រឱ្យគណបក្សណាមួយឡើយ ។





អ្នកបោះឆ្នោតគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់

អ្នកបោះឆ្នោត ត្រូវគូសសញ្ញាគាំទ្រមួយ
នៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយតែ ១គត់
ដែលអ្នកពេញចិត្ត ដោយប្រើប៊ិកដែលមានក្នុងបន្ទប់សម្ងាត់ស្រាប់
ឬក៏អាចប្រើប៊ិកផ្ទាល់ខ្លួន លើកលែងតែខ្មៅដៃ ។






ការគូសសន្លឹកឆ្នោតដែលមិនត្រឹមត្រូវ



មុននឹងចេញពីបន្ទប់សម្ងាត់
អ្នកបោះឆ្នោតត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម
រួចដើរទៅកាន់តុដាក់ហិបឆ្នោត លើកសន្លឹកឆ្នោតដែល
បត់រួចហើយ និងមានត្រាសម្ងាត់នៅខាងខ្នងបង្ហាញ
សមាជិកទី១ ដែលនៅក្បែរនោះ រួចស៊កសន្លឹកឆ្នោតតាម
ប្រឡោះតូចចូលទៅក្នុងហិបឆ្នោត ។






ការស៊កសន្លឹកឆ្នោតចូលទៅក្នុងហិបឆ្នោត

បន្ទាប់មក អ្នកបោះឆ្នោតត្រូវជ្រលក់
ម្រាមចង្អុលដៃស្ដាំទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ ។






ជួបសមាជិកទី១ ដើម្បីជ្រលក់ម្រាមចង្អុលដៃស្ដាំ
ទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ

បន្ទាប់មក អ្នកបោះឆ្នោត
ដើរចេញពីការិយាល័យបោះឆ្នោត ជាការស្រេច ។






អ្នកបោះឆ្នោតដើរចេញពីការិយាល័យបោះឆ្នោត


១
យើងត្រូវដឹងថា សន្លឹកឆ្នោតយើង
គឺជាសន្លឹកឆ្នោតសម្ងាត់ គ្មានជនណាម្នាក់ដឹងថា
យើងបោះឆ្នោតជូនគណបក្សនយោបាយណាមួយឡើយ ។
បើមានជនណាម្នាក់មកសួរយើងថា
បោះឆ្នោតឱ្យគណបក្សណាមួយនោះ យើងមិនត្រូវ
ប្រាប់គេឡើយ ព្រោះវាជាការសម្ងាត់របស់យើង។
២
អូហ៎.....ខ្ញុំយល់ហើយ !